# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងឧស្សាហកម្ម និង សិប្បកម្ម**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ : ០៦៥ ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី ការដាក់មន្ត្រី និយោជិត ឲ្យចូលនិវត្តន៍

## អគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

- បានឃើញព្រះរាជក្រមលេខ ០៦៩/០៣ ចុះថ្ងៃទី ១៧-០៦-៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩-១២-៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១២-០៦-០០ ស្ដីពីការកែសំរួលអនុក្រឹត្យលេខ ៥២ អនក្រ.ប.ក ។
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤-០៥-០៤ ស្ដីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអោយស្ថិតនៅក្រោមអាណាព្យាបាល នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៦៦៤ អនក្រ.តត ចុះថ្ងៃទី ០៨-០៦-១២ ស្ដីពីការតែងតាំងអគ្គនាយក រ.ទ.ស.ភ ។
- បានឃើញអនុសញ្ញាស្ដីពីការចូលនិវត្តន៍ និង បាត់បង់សម្បទាវិជ្ជាជីវៈចំពោះ មន្ត្រី-និយោជិត នៃ រ.ទ.ស.ភ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលអាណត្តិទី៣ នាសម័យប្រជុំលើកទី៦ កាលពីថ្ងៃទី ២៨-០៩-០៧ ។
- បានឃើញលក្ខន្តិកៈបុគ្គលិក រ.ទ.ស.ភ កែសំរួលលើកទី៣ និង អនុម័តដោយក្រុមប្រឹក្សាភិបាលអាណត្តិទី៤ នាសម័យប្រជុំលើកទី១៧ កាលពីថ្ងៃទី ២៦-០៦-២០១២ ។
- ពាក្យសុំទទួលរបបសោធននិវត្តន៍ចុះថ្ងៃទី ១៨/០៨/២០១៤ ។

## សម្រេច

**ប្រការ ១** : យល់ព្រមអោយលោក **ឡាច បវណ្ណា** ជនជាតិខ្មែរ កើតថ្ងៃទី ២៩/០៨/១៩៥៤ឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ បានចូលនិវត្តន៍ ដែលមានរយៈពេលបំពេញការងាររួមចំនួន ៣៤ឆ្នាំ ០៧ខែ គិតត្រឹមថ្ងៃទី ៣១-០៨-២០១៤ (ស្មើនិង៣៥ឆ្នាំ) ក្នុងនោះមាន៖
- រយៈពេលបំពេញការងារពីថ្ងៃទី ០១-០២-៨០ ដល់ថ្ងៃទី ០១-១១-៩៣ ចំនួន ១៣ឆ្នាំ ០៩ខែ ធ្វើការនៅមន្ទីរពាណិជ្ជកម្មរាជធានី។
- រយៈពេលបំពេញការងារពីថ្ងៃទី ០១-១១-៩៣ ដល់ថ្ងៃទី ២៥-០៩-៩៧ ចំនួន ០៣ឆ្នាំ ១០ខែ ២៥ថ្ងៃ ធ្វើការនៅ រ.ទ.ភ.ព ។
- រយៈពេលបំពេញការងារពីថ្ងៃទី ២៥-០៩-៩៧ ដល់ថ្ងៃទី ៣១-០៨-១៤ ចំនួន ១៦ឆ្នាំ ១១ខែ ០៦ថ្ងៃ ធ្វើការនៅ រ.ទ.ស.ភ ។
- មុខងារមុនពេលចូលនិវត្តន៍ ៖ ប្រធាននាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ
- ស្ថាប័នមុនពេលចូលនិវត្តន៍ ៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- អាស័យដ្ឋានក្រោយពេលចូលនិវត្តន៍ ៖ ផ្ទះលេខ១៨៣A ផ្លូវ២៧១ ភូមិអូរបែកក្អម សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ក្រុងភ្នំពេញ
- ថ្នាក់-កាំបៀវត្សរ៍ មុនពេលចូលនិវត្តន៍ ៖ ថ្នាក់ ៩ កាំ ១១ ( ៥,៦១៣,៣១២ ៛០០ )
- ដាក់អោយចូលនិវត្តន៍ ចាប់ពីថ្ងៃទី ០១-០៩-២០១៤ នេះតទៅ ។

**ប្រការ ២** : លោក **ឡាច បវណ្ណា** ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

ក- ប្រាក់ឧបត្ថម្ភតែម្ដងគត់ ស្មើនឹងប្រាក់បៀវត្សរ៍សុទ្ធប្រចាំខែចំនួន ៥,៦១៣,៣១២៛ x ៦ខែ = **៣៣,៦៧៩,៨៧២ ៛០០** ( សាមសិបបីលាន ប្រាំមួយរយចិតសិបប្រាំបួនពាន់ ប្រាំបីរយចិតសិបពីររៀលគត់ ) ។

ខ- ប្រាក់សោធននិវត្តន៍ប្រចាំខែស្មើនឹង ៤៤% នៃប្រាក់បៀវត្សរ៍សុទ្ធសាជចុងក្រោយរហូតដល់មានការកែប្រែច្បាប់សាជាថ្មី ឬ អវសានជីវិត ដែលគិតជាទឹកប្រាក់ចំនួន **២,៤៦៩,៨៥៧ ៛** ( ពីរលាន បួនរយហុកសិបប្រាំបួនពាន់ ប្រាំបីរយហាសិបប្រាំពីររៀលគត់ ) ។

**ប្រការ ៣** : នាយកដ្ឋាន រ.ប.ធ, នាយកដ្ឋាន គ.ន.ហ.វ, ការិយាល័យធនធានមនុស្ស និង គ្រប់នាយកដ្ឋាន ការិយាល័យ/អង្គភាពពាក់ព័ន្ធព្រមទាំងសាមីខ្លួនដូចមានឈ្មោះ ក្នុងប្រការ "១" ត្រូវទទួលបន្ទុកអនុវត្តនូវសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤** : សេចក្ដីសម្រេចនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ៨៧ ឆ្នាំ ២០១៤
**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>កន្លែងទទួល</u>
- ដូចក្នុងប្រការ៣ "ដើម្បីអនុវត្ត-មុខការ"
- កាលប្បវត្ត-ឯកសារ